អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អៀង ធិរិទ្ធ ហៅ ភា



**គោត្តនាម** ៖ អៀង | **នាម** ៖ ធីរិទ្ធ

**លេខសំណុំរឿង** ៖ ០០២/១៩-០៩-២០០៧/អវតក-អជសដ

**សវនាការសាធារណៈលើកក្រោយ** ៖ ២៧ មិថុនា ២០១១

**កាលបរិច្ឆេទនិងទីកន្លែងកំណើត** ៖ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅទីក្រុងភ្នំពេញ

**ចាប់ខ្លួន** ៖ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧

**មេធាវីការពារក្តី** ៖ លោក ផាត់ ពៅស៊ាង (មេធាវីជាតិ) និងលោកស្រី ដាយអាណា អេលីស (Diana Ellis) (មេធាវីអន្តរជាតិ ជនជាតិអង់គ្លេស)

| | |
|---|---|
| ស្ថានភាពបច្ចុប្បន្ន | ត្រូវចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះពីបទ **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា** ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងមានចែងនិងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី) មាត្រា៤, ៥, ៦, ២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ សវនាការបឋមនឹងចាប់ផ្តើមនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។ |
| តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច |

| | |
|---|---|
| **បទចោទប្រកាន់សំខាន់ៗ** | អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវដោយផ្ទាល់ក្នុងការរៀបចំផែនការ សមគំនិត ជំរុញ និងបង្កលក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោម៖<br><br>**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** ៖ មនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងផ្នែកនយោបាយនិងសាសនា និងអំពើអមនុស្សធម៌ផ្សេងទៀត។<br><br>**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** ៖ ការសម្លាប់ក្រុមជនជាតិវៀតណាម។<br><br>**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖** មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មឬការធ្វើទុក្ខបុកម្នេញ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរឬឲ្យមានការឈឺចាប់ដល់រូបរាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ការបង្ខាំងនិងការនិរទេសជនស៊ីវិលដោយខុសច្បាប់។<br><br>អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវដោយផ្ទាល់ក្នុងនាមជាថ្នាក់ដឹកនាំ ឬបានចេញបញ្ជារ ចំពោះការប្រព្រឹត្ត៖<br><br>**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** ៖ ចំពោះអំពីអមនុស្សធម៌ផ្សេងៗទៀតនិងការរើសអើងពូជសាសន៍។<br><br>អៀង ធីរិទ្ធ ក៏ត្រូវបានចោទប្រកាន់ថា មានការទទួលខុសត្រូវដោយប្រយោលក្នុងឧក្រិដ្ឋកម្មរួម ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។<br><br>ជាងនេះទៅទៀត អៀង ធីរិទ្ធ ជាប់ចោទពីបទមនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ |

**ប្រវត្តិរូបផ្ទាល់ខ្លួន**

អៀង ធីរិទ្ធ បានបញ្ចប់ការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ ក្រុងភ្នំពេញ បន្ទាប់មកគាត់បានទៅសិក្សាផ្នែកអក្សរសាស្ត្រនៅសាកលវិទ្យាល័យ សបូន (Sorbonne) នៅប្រទេសបារាំង។ គាត់គឺជាស្ត្រីកម្ពុជាទីមួយដែលបានទទួលសញ្ញាប័ត្រផ្នែកអក្សរសាស្ត្រអង់គ្លេស។ អៀង ធីរិទ្ធ បានត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៥៧ និងបានធ្វើជាសាស្ត្រាចារ្យមុនពេលបង្កើតសាលាឯកជនបង្រៀនភាសាអង់គ្លេសមួយនៅឆ្នាំ១៩៦០។

នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ អៀង ធីរិទ្ធ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អៀង ធិរិទ្ធ ត្រូវបានចោទថាបានធ្វើការជាមួយខ្មែរក្រហម រហូតដល់ពេលដែលស្វាមីរបស់គាត់ គឺលោក អៀង សារី បានទទួលការលើកលែងទោសពីព្រះមហាក្សត្រកម្ពុជានៅឆ្នាំ១៩៩៨។ គាត់និងប្តីបានមករស់នៅក្នុងទីក្រុងភ្នំពេញ រហូតដល់ពេលត្រូវប៉ូលិសចាប់ខ្លួន និងបញ្ជូនមកឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក នៅខែវិច្ឆិកា ឆ្នាំ២០០៧។

| | | |
|---|---|---|
| **ប្រវត្តិនៃសំណុំរឿង** | ១២ វិច្ឆិកា ២០០៧ | អៀង ធីរិទ្ធ ត្រូវចាប់និងឃុំខ្លួនក្រោមអំណាចរបស់នគរបាលយុត្តិធម៌ |
| | ១៤ វិច្ឆិកា ២០០៧ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចឃុំខ្លួន អៀង ធីរិទ្ធ ជាបណ្តោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំ |
| | ៨ មករា ២០០៨ | អៀង ធីរិទ្ធ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះប្រឆាំងនឹងដីកាឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ៩ កក្កដា ២០០៨ | អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១០ វិច្ឆិកា ២០០៨ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចពន្យារពេលឃុំខ្លួន អៀង ធីរិទ្ធ ជាបណ្តោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំទៀត |

| | | |
|---|---|---|
| | ៩ ធ្នូ ២០០៨ | អៀង ធីរិទ្ធ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១១ ឧសភា ២០០៩ | អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១០ វិច្ឆិកា ២០០៩ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចពន្យារពេលឃុំខ្លួន អៀង ធីរិទ្ធ ជាបណ្តោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំទៀត |
| | ៩ ធ្នូ ២០០៩ | អៀង ធីរិទ្ធ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យារ ពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១៤ មករា ២០១០ | សហចៅក្រមស៊ើបអង្កេតចេញសេចក្តីជូនដំណឹងទៅ អៀង ធីរិទ្ធ អំពីការពិចារណារបស់សហចៅក្រមស៊ើបអង្កេតក្នុងការ ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការស៊ើបអង្កេត |
| | ៣០ មេសា ២០១០ | អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១៩ កក្កដា ២០១០ | សហចៅក្រមស៊ើបអង្កេតបញ្ជូនឯកសារសំណុំរឿងទៅសហ ព្រះរាជអាជ្ញា ដើម្បីឲ្យសហព្រះរាជអាជ្ញារៀបចំសេចក្តី សន្និដ្ឋានស្ថាពរ |
| | ១៦ សីហា ២០១០ | សហព្រះរាជអាជ្ញាចេញសេចក្តីសន្និដ្ឋានស្ថាពរ និងលើក សំណើទៅសហចៅក្រមស៊ើបអង្កេតឲ្យចោទប្រកាន់ អៀង ធីរិទ្ធ និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| | ១៥ កញ្ញា ២០១០ | សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ដោយចោទ ប្រកាន់ អៀង ធីរិទ្ធ និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ អៀង ធីរិទ្ធ ត្រូវបានបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្ន រហូតដល់ពេលដែលត្រូវនាំយកទៅជំនុំជម្រះនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង។ |

## ព័ត៌មានទាក់ទងនឹងសំណុំរឿង

| | | |
|---|---|---|
| | ១៨ តុលា ២០១០ | អៀង ធីរិទ្ធ ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងយុត្តាធិការនៃដីកាដំណោះស្រាយ |
| | ១៣ មករា ២០១១ | អង្គបុរេជំនុំជម្រះបានបញ្ជាក់និងធ្វើវិសោធនកម្មដោយផ្នែកទៅលើបទចោទប្រកាន់ប្រឆាំងនឹង អៀង ធីរិទ្ធ ដែលមានចែងនៅក្នុងដីកាដំណោះស្រាយនិងសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ អៀង ធីរិទ្ធ ត្រូវបានបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្នរហូតដល់ពេលដែលត្រូវនាំយកទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ |
| | ២១ មករា ២០១១ | អៀង ធីរិទ្ធ ដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះសាលាដំបូងទាមទារដោះលែងរូបគាត់ឲ្យនៅក្រៅឃុំ |
| | ១៦ កុម្ភៈ ២០១១ | អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណូមពរនៅក្រៅឃុំរបស់ អៀង ធីរិទ្ធ |

*ដីកា និងសេចក្តីសម្រេចទាំងនេះ និងផ្សេងៗទៀត សូមមើល:

http://www.eccc.gov.kh/document/court

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានទាក់ទងនឹងសំណុំរឿងនេះរៀបចំដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ដើម្បីជាជំនួយដល់សាធារណជន ឲ្យមានការយល់ដឹងអំពីសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក។ ឯកសារនេះពុំមែនជាឯកសារផ្លូវការផ្នែកច្បាប់ណាមួយនោះទេ បើទោះបីជាមានការខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីធានាដល់តម្លាភាពព័ត៌មានក៏ដោយ។

**អាសយដ្ឋាន:** ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ប្រអប់សំបុត្រលេខ៧១
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥)២៣ ២១៩ ៨១៤
ទូរសារ: (៨៥៥) ២៣ ២១៩ ៨៤១
សារអេឡិកត្រូនិក: pas@eccc.gov.kh